**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងបរិស្ថាន**
លេខ :...០១០...សសណន.....ប.ស្ត

# សេចក្តីណែនាំ
## ស្តីពី
## សម្រាប់ការរៀបចំ «សម្ព័ន្ធភាពសហគមន៍អភិរក្សធនធានធម្មជាតិ »

**យោង** ៖- ព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ
- ព្រះរាជក្រមលេខ នស/រកម/០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល
- លិខិតលេខ ៩៦៨ សជណ.កស ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

ក្រសួងបរិស្ថាន នឹងសម្របសម្រួលរៀបចំបង្កើត សម្ព័ន្ធភាពសហគមន៍អភិរក្សធនធានធម្មជាតិ ជាមួយស្ថាប័នពាក់ព័ន្ធ ជាពិសេសរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាយន្តការមួយរួមចំណែក ធ្វើឱ្យប្រសើរឡើងក្នុងការពង្រឹងការងារ ការការពារ និងអភិរក្សធនធានធម្មជាតិ និងជីវៈចម្រុះនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ សម្ព័ន្ធភាពនេះ នឹងបង្កើនកិច្ចសហការឱ្យកាន់តែរឹងមាំ និងមានប្រសិទ្ធភាព រវាងសហគមន៍តំបន់ការពារធម្មជាតិ អាជ្ញាធរដែនដី ស្ថាប័នជំនាញ អង្គការដៃគូ និងវិស័យឯកជន តាមរយៈការចែករំលែកព័ត៌មាន បទពិសោធន៍ និងចំណេះដឹង ដើម្បីរួមគ្នាស្វែងរកយន្តការចាំបាច់សម្រាប់ដោះស្រាយបញ្ហានានា ដែលទាក់ទងនឹងការការពារ និងអភិរក្សធនធានធម្មជាតិ។

ដើម្បីសម្រេចបានក្នុងការរៀបចំបង្កើត សម្ព័ន្ធភាពសហគមន៍អភិរក្សធនធានធម្មជាតិ នេះ ក្រសួងបរិស្ថាន សូមធ្វើការណែនាំនូវចំណុចមួយចំនួនដូចខាងក្រោម៖

១. ត្រូវរៀបចំ សម្ព័ន្ធភាពសហគមន៍អភិរក្សធនធានធម្មជាតិ ឱ្យស្របតាមលិខិតបទដ្ឋានច្បាប់នៃព្រះរាជាណាចក្រកម្ពុជា
២. ត្រូវធ្វើការយ៉ាងជិតស្និទ្ធិជាមួយអាជ្ញាធរដែនដី ស្ថាប័នជំនាញ អង្គការដៃគូ វិស័យឯកជន និងសហគមន៍តំបន់ការពារធម្មជាតិ ដោយមានការសម្របសម្រួលពីអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន ក្នុងការរៀបចំបង្កើត សម្ព័ន្ធភាពសហគមន៍អភិរក្សធនធានធម្មជាតិ

៣. ត្រូវរៀបចំ សម្ព័ន្ធភាពសហគមន៍អភិរក្សធនធានធម្មជាតិ នៅកម្រិតមូលដ្ឋាន (ឧទ្យានជាតិឬដែនជម្រកសត្វព្រៃ) កម្រិតខេត្ត និងកម្រិតជាតិ និងរចនាសម្ព័ន្ធគ្រប់គ្រងរបស់ សម្ព័ន្ធភាពសហគមន៍អភិរក្សធនធានធម្មជាតិ

៤. ត្រូវជ្រើសរើសអ្នកដឹកនាំ នៃសម្ព័ន្ធភាពសហគមន៍អភិរក្សធនធានធម្មជាតិ តាមរយៈការបោះឆ្នោត ជ្រើសចេញពីគណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ ទៅតាមលំដាប់លំដោយពីកម្រិតមូលដ្ឋាន កម្រិតខេត្ត និងកម្រិតជាតិ ដោយមានការជួយសម្របសម្រួលពីអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន និងរដ្ឋបាលថ្នាក់ក្រោមជាតិ

៥. ត្រូវរៀបចំលក្ខន្តិកៈ នៃសម្ព័ន្ធភាពសហគមន៍អភិរក្សធនធានធម្មជាតិ ដោយមានការចូលរួមពិគ្រោះយោបល់ពីអ្នកពាក់ព័ន្ធ និងស្របតាមច្បាប់ ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល

៦. ត្រូវលើកទឹកចិត្តដល់ អាជ្ញាធរមូលដ្ឋាន ស្ថាប័នជំនាញពាក់ព័ន្ធ អង្គការដៃគូ និងវិស័យឯកជន ដើម្បីចូលរួមក្នុងការរៀបចំលក្ខន្តិកៈ នៃសម្ព័ន្ធភាពសហគមន៍អភិរក្សធនធានធម្មជាតិ

៧. គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍មូលដ្ឋានផ្សេងទៀតដែលស្ម័គ្រចិត្ត ត្រូវចូលរួមក្នុងដំណើរការរៀបចំ និងការអនុវត្តសកម្មភាព នៃសម្ព័ន្ធភាពសហគមន៍អភិរក្សធនធានធម្មជាតិ។

គ្រប់នាយកដ្ឋានជំនាញពាក់ព័ន្ធក្រោមឱវាទក្រសួងបរិស្ថាន មន្ទីរបរិស្ថាន រដ្ឋបាលថ្នាក់ក្រោមជាតិ គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍មូលដ្ឋាន ត្រូវអនុវត្តសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ សុក្រ ៥ រោច ខែ មិគសិរ ឆ្នាំរកា ព.ស ២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ ធ្នូ គ.ស ២០១៧

**រដ្ឋមន្ត្រី**

**សាយ សំអាល់**

**ចម្លងជូន:**

- គ្រប់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ
- គ្រប់រដ្ឋបាលសាលាខេត្ត ស្រុក ខណ្ឌ ឃុំ
- គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងបរិស្ថាន
- មន្ទីរបរិស្ថាន
- សហគមន៍តំបន់ការពារធម្មជាតិ
- ដើម្បីជ្រាប និងសហការអនុវត្ត